ជំពូកទី ១៨

# ប្រព័ន្ធទឹកនោម និងប្រដាប់បន្តពូជ

**ប្រព័ន្ធទឹកនោម** ឬបំពង់ទឹកនោម ធ្វើការក្នុងរាងកាយដោយសម្អាតសារធាតុសំណល់ពីក្នុងឈាម ហើយបញ្ចេញចោលក្នុងទម្រង់ជា ***ទឹកនោម*** ៖




## ប្រដាប់បន្តពូជគឺជាសរីរាង្គភេទ

### បុរស




### ស្ត្រី



# បញ្ហានៃប្រព័ន្ធទឹកនោម

មានបញ្ហាផ្សេងៗគ្នាជាច្រើន ទាក់ទងនឹងប្រព័ន្ធទឹកនោម។ បញ្ហាទាំងនោះពិបាកនឹងញែកឲ្យដាច់ពីគ្នាណាស់។ ហើយជំងឺតែមួយអាចបង្ហាញរោគសញ្ញាផ្សេងគ្នា លើបុរសនិងស្ត្រី។ ក្នុងចំណោមបញ្ហាទាំងនោះ បញ្ហាមួយចំនួនមិនមានសភាពធ្ងន់ធ្ងរទេ ប៉ុន្តែមួយចំនួនទៀតអាចមានគ្រោះថ្នាក់យ៉ាងខ្លាំង។ ជំងឺដ៏គ្រោះថ្នាក់ខ្លះ អាចចាប់ផ្តើមដោយមានរោគសញ្ញាស្រាលៗតែប៉ុណ្ណោះ។ ការសម្គាល់ជំងឺទាំងនោះឲ្យបានត្រឹមត្រូវដោយការប្រើសៀវភៅមួយក្បាលដូចជាសៀវភៅនេះ ពិតជាមានការពិបាកណាស់។ គេអាចត្រូវការចំណេះដឹង និងការធ្វើតេស្តពិសេសជាច្រើនទៀត។ បើអាច ស្វែងរកដំបូន្មានពីបុគ្គលិកសុខាភិបាល។

**បញ្ហានៃប្រព័ន្ធទឹកនោម**ដែលកើតជាញឹកញាប់ រួមមាន ៖

១. ការបង្ករោគនៅបំពង់ទឹកនោម។ បញ្ហានេះកើតជាញឹកញាប់បំផុតលើស្ត្រី។ (ជួនកាលវាកើតឡើងក្រោយពេលមានការរួមភេទ ប៉ុន្តែវាក៏អាចកើតឡើងនៅពេលផ្សេងទៀតដែរ ជាពិសេសក្នុងពេលមានផ្ទៃពោះ)។

២. គ្រួសក្នុងតម្រងនោម ឬគ្រួសក្នុងប្លោកនោម។

៣. ជំងឺក្រពេញប្រ៉ូស្តាត (ពិបាកនោម បណ្តាលមកពីការរីកធំនៃក្រពេញនេះ ហើយច្រើនកើតលើបុរសវ័យចំណាស់)។

៤. ជំងឺប្រមេះទឹកបាយ (ជំងឺឆ្លងដែលឆ្លងតាមការរួមភេទ ដែលភាគច្រើនធ្វើឲ្យពិបាកឬមានការឈឺចាប់ពេលនោម)។

៥. នៅតាមតំបន់ខ្លះក្នុងពិភពលោក ជំងឺស៊ីស្តូសូមីយ៉ាស៊ីស(Schistosomiasis)គឺជាមូលហេតុញឹកញាប់បំផុតដែលឲ្យមានឈាមក្នុងទឹកនោម។ ជំងឺនេះត្រូវបានពិភាក្សានៅក្នុងផ្នែកជំងឺព្រូនផ្សេងៗ សូមមើលទំព័រ១៤៦។

## ការបង្ករោគនៅប្រព័ន្ធទឹកនោម

*រោគសញ្ញា ៖*

- ជួនកាលមានគ្រុនក្តៅនិងញាក់ ឬឈឺក្បាល
- ជួនកាលមានការឈឺចាប់នៅចំហៀងខ្លួន
- នោមឈឺ និងចង់នោមជាញឹកញាប់
- មិនអាចទប់ទឹកនោមបាន (ជាពិសេសចំពោះកុមារតូចៗ)
- ទឹកនោមអាចមានពណ៌ល្អក់ ឬក្រហម(មានឈាម)



- ជួនកាលមានអារម្មណ៍ថា មានទឹកនោមនៅសល់ក្នុងប្លោកនោម
- ជួនកាលមានការឈឺចង្កេះ នៅផ្នែកខាងក្រោមនៃខ្នង (តម្រងនោម)។
- ជួនកាល ការឈឺចាប់ហាក់ដូចជាចុះក្រោម ទៅជើង
- ក្នុងករណីធ្ងន់ធ្ងរ (ជំងឺតម្រងនោម) ជើងនិងមុខអាចហើម

មានស្ត្រីជាច្រើនមានការបង្ករោគនៅប្រព័ន្ធទឹកនោម។ បញ្ហានេះមិនសូវមានលើបុរសទេ។ ជួនកាល រោគសញ្ញាមានតែ **នោមឈឺ** និង**ការចង់នោមជាញឹកញាប់**។ រោគសញ្ញាផ្សេងៗទៀតដែលមានជាញឹកញាប់ មានដូចជា មាន**ឈាមនៅក្នុងទឹកនោម** និងមានការ**ឈឺចាប់ក្នុងពោះ ផ្នែកខាងក្រោម**។ ការឈឺចាប់នៅខ្នង ផ្នែកកណ្តាលឬខាងក្រោម ដែលច្រើនតែរាលដាលដល់ម្តុំចំហៀង ខាងក្រោមឆ្អឹងជំនីរ ដោយមានគ្រុនក្តៅផងនោះ បញ្ជាក់ថាមានបញ្ហាធ្ងន់ធ្ងរ។

*ការព្យាបាល ៖*



- **ផឹកទឹកឲ្យបានច្រើន។** ការបង្ករោគស្រាលៗមួយចំនួន អាចជាសះស្បើយដោយគ្រាន់តែផឹកទឹកឲ្យបានច្រើន ដោយមិនចាំបាច់ប្រើថ្នាំពេទ្យទេ។ ផឹកទឹកយ៉ាងតិចមួយកែវរៀងរាល់៣០នាទីម្តង ក្នុងរយៈពេលបីទៅបួនម៉ោង ហើយទម្លាប់ផឹកទឹកឲ្យបានច្រើនរបៀបនេះ។ (ប៉ុន្តែបើអ្នកនោះមិនអាចនោមបាន ឬមានហើមដៃនិងមុខ នោះគាត់មិនគួរផឹកទឹកច្រើនទេ)។
- បើអ្នកជំងឺគ្មានការធូរស្រាលដោយការផឹកទឹកច្រើននោះទេ ឬគាត់មានគ្រុនក្តៅ នោះគាត់គួរលេបថ្នាំកូទ្រីម៉ុកសាហ្សូល(Cotrimoxazole) ឬស៊ុលហ្វូណាមីដ(Sulfonamide) (ទំ.៣៥៨) ឬអំពីស៊ីលីន(ទំ.៣៥៣) ឬតេត្រាស៊ីគ្លីន(ទំ.៣៥៦)។ ត្រូវយកចិត្តទុកដាក់ចំពោះកម្រិតប្រើ និងការប្រុងប្រយ័ត្ននៃថ្នាំ។ ដើម្បីព្យាបាលការបង្ករោគឲ្យជាជាស្ថាពរ អ្នកអាចត្រូវការលេបថ្នាំរយៈពេល១០ថ្ងៃ ឬលើសពីនេះ។ ការសំខាន់គឺត្រូវផឹកទឹកឲ្យបានច្រើនក្នុងពេលលេបថ្នាំទាំងនេះ ជាពិសេសថ្នាំស៊ុលហ្វូណាមីដ។
- បើអ្នកជំងឺគ្មានការធូរស្រាលយ៉ាងឆាប់រហ័សទេ ស្វែងរកជំនួយពីគ្រូពេទ្យ។
- ថ្នាំថ្មីៗមួយចំនួន អាចបំបាត់ការឈឺចាប់បានទាំងស្រុង ប៉ុន្តែ**មិនបានព្យាបាល**ការបង្ករោគនៅប្រព័ន្ធទឹកនោមនេះទេ។ កុំប្រើថ្នាំប្រភេទនេះលើសពីពីរថ្ងៃ។

## គ្រួសក្នុងតម្រងនោម ឬគ្រួសក្នុងប្លោកនោម

*រោគសញ្ញា ៖*

- ភាគច្រើនរោគសញ្ញាដំបូងគឺការឈឺចាប់ភ្លាមៗហើយខ្លាំង នៅខ្នងផ្នែកខាងក្រោម នៅចំហៀង ឬនៅពោះផ្នែកខាងក្រោម ឬនៅគល់លិង្គ ចំពោះបុរស។
- ជួនកាលបំពង់នោមត្រូវបានស្ទះ ដូច្នេះអ្នកជំងឺមានការពិបាកក្នុងការនោម ឬនោមមិនចេញ។ ឬអាចមានដំណក់ឈាមស្រក់ចេញមកក្រៅ នៅពេលចាប់ផ្តើមនោម។
- ជួនកាលក៏អាចមានការបង្ករោគនៅប្រព័ន្ធទឹកនោម ក្នុងពេលជាមួយគ្នានេះដែរ។

*ការព្យាបាល ៖*

- ដូចគ្នានិងការបង្ករោគនៅប្រព័ន្ធទឹកនោម ដែលបានរៀបរាប់ខាងលើ។
- ថែមទាំងឲ្យថ្នាំអាស្ពីរីន(Aspirin) ឬថ្នាំបំបាត់ការឈឺចាប់ផ្សេងទៀត ព្រមទាំងពពួកថ្នាំអង់ទីស្ប៉ាស្មូដិច (antispasmodic) (ទំ.៣៨១)។
- បើអ្នកមិនអាចនោមបាន សាកល្បងដេកនោមម្តង។ ជួនកាលការធ្វើរបៀបនេះ ធ្វើឲ្យគ្រួសនៅក្នុងប្លោកនោមរមៀលចេញពីផ្លូវបំពង់នោម។
- ក្នុងករណីធ្ងន់ធ្ងរ ស្វែងរកជំនួយពីគ្រូពេទ្យ។ ជួនកាលគេត្រូវការការវះកាត់។

## ជំងឺរីកក្រពេញប្រូស្តាត

បញ្ហានេះកើតឡើងញឹកញាប់ចំពោះបុរសដែលមានអាយុលើសពី៤០ឆ្នាំ។ ជំងឺនេះបណ្តាលមកពីការរីកក្រពេញប្រូស្តាត ដែលស្ថិតនៅចន្លោះប្លោកនោម និងបង្ហូរនោម។

- អ្នកជំងឺមានការពិបាកក្នុងការនោម ហើយជួនកាលពិបាកក្នុងការបន្ទោរបង់លាមកទៀតផង។ ទឹកនោមអាចចេញតក់ៗ ឬស្ទះទាំងស្រុងតែម្តង។ ជួនកាលអ្នកជំងឺនោមមិនចេញជាច្រើនថ្ងៃ។
- បើគាត់មានគ្រុនក្តៅ នេះជារោគសញ្ញានៃការមានការបង្ករោគផងដែរ។



*ការព្យាបាលជំងឺរីកក្រពេញប្រ៉ូស្តាត ៖*

- បើអ្នកជំងឺនោមមិនចេញ គាត់គួរសាកល្បងអង្គុយត្រាំក្នុងទឹកក្តៅ ដូចរូបនេះ បើការធ្វើរបៀបនេះមិនមានលទ្ធផលល្អទេ នោះគេប្រហែលជាត្រូវការប្រើបំពង់បូមទឹកនោម(ទំ.២៣៩)។
- បើគាត់មានគ្រុនក្តៅ ត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាអំពីស៊ីលីន(ទំ.៣៥៣) ឬតេត្រាស៊ីគ្លីន(ទំ.៣៥៦)។
- ស្វែងរកជំនួយពីគ្រូពេទ្យ។ ករណីធ្ងន់ធ្ងរឬរ៉ាំរ៉ៃ អាចត្រូវការការវះកាត់។

*ចំណាំ ៖* ទាំងបញ្ហាក្រពេញប្រ៉ូស្តាត និងជំងឺប្រមេះទឹកបាយ អាចធ្វើឲ្យពិបាកនោមដូចគ្នា។ មនុស្សប្រុសចាស់ទំនងជាមានបញ្ហារីកក្រពេញប្រ៉ូស្តាតច្រើនជាង។ ចំណែកឯមនុស្សប្រុសវ័យក្មេង ជាពិសេសអ្នកដែលមានការរួមភេទក្នុងពេលថ្មីៗជាមួយអ្នកមានជំងឺកាមរោគ ប្រហែលជាកើតជំងឺប្រមេះទឹកបាយ។

## ការបង្ករោគដែលឆ្លងតាមការរួមភេទ (ជំងឺកាមរោគ)

នៅទំព័របន្តបន្ទាប់នេះ យើងពិភាក្សាអំពីជំងឺកាមរោគមួយចំនួនដូចជា **ប្រមេះទឹកបាយ ក្លាមីដ្យា ស្វាយ និងការហើមកូនកណ្តុរនៅក្រលៀន។ មេរោគអេដស៍/ជំងឺអេដស៍** និងជំងឺកាមរោគមួយចំនួនទៀតដែលបណ្តាលឲ្យមានដំបៅនៅលើប្រដាប់ភេទ(**ពងទឹក សិរមាន់** និង**ទាមឡា**) ត្រូវបានពិភាក្សានៅទំព័រខៀវ។ មើលទំ.៣៩៩ ទៅ៤០៣។

## ជំងឺប្រមេះទឹកបាយ និងក្លាមីដ្យា

**បុរសនិងស្ត្រី អាចមានជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យាដោយគ្មានរោគសញ្ញាអ្វីទាំងអស់។** ជំងឺប្រមេះទឹកបាយ និងក្លាមីដ្យា អាចមានរោគសញ្ញាដូចគ្នា ប៉ុន្តែជាទូទៅជំងឺប្រមេះទឹកបាយចាប់ផ្តើមលឿនជាង និងមានការឈឺចាប់ជាង។ បុរសនិងស្ត្រីអាចមានជំងឺប្រមេះទឹកបាយ និងក្លាមីដ្យាក្នុងពេលតែមួយ ដូច្នេះជាការប្រសើរ គួរព្យាបាលជំងឺទាំងពីរមុខនេះក្នុងពេលជាមួយគ្នា។ បើមិនព្យាបាលទេ ជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា អាចធ្វើឲ្យបុរសឬស្ត្រីមិនអាចមានកូនបាន។

បើស្ត្រីមានផ្ទៃពោះ កើតជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា ហើយមិនបានព្យាបាលមុនពេលសម្រាលកូនទេ ការបង្ករោគនឹងឆ្លងទៅដល់ភ្នែករបស់ទារក ហើយធ្វើឲ្យទារកខ្វាក់(មើលទំ.២២១)។

*រោគសញ្ញាចំពោះបុរស ៖*

- ស្រក់ខ្ទុះចេញពីលិង្គ
- ជួនកាលមានហើមនិងឈឺចាប់នៅពងស្វាស



*រោគសញ្ញាចំពោះបុរស និងស្ត្រីទាំងពីរភេទ ៖*

- មានការឈឺចាប់ ឬក្រហាយនៅពេលនោម
- មានកន្ទួលឬដំបៅពេញខ្លួន
- មានហើម និងឈឺចាប់នៅជង្គង់ កជើង ឬកដៃ តែម្ខាងឬទាំងពីរ

*រោគសញ្ញាចំពោះស្ត្រី ៖*

- មានហូរខ្ទុះពណ៌ខៀវឬលឿងពីទ្វារមាស ឬទ្វារលាមក
- មានការឈឺចាប់នៅក្នុងពោះផ្នែកខាងក្រោម (រលាកអាងត្រគាក ទំ.២៤៣)
- មានគ្រុនក្តៅ
- ឈឺចាប់នៅពេលរួមភេទ



ចំពោះបុរស សញ្ញាដំបូងចាប់ផ្ដើមពី២ទៅ៥ថ្ងៃ (ឬ៣អាទិត្យ ឬលើសពីនេះ) បន្ទាប់ពីបានរួមភេទជាមួយអ្នកមានជំងឺកាមរោគរួច។ ចំពោះស្ត្រីវិញ រោគសញ្ញាប្រហែលជាមិនបង្ហាញឡើងក្នុងរយៈពេលជាច្រើនអាទិត្យ ឬច្រើនខែ។ ប៉ុន្តែចំពោះ**មនុស្សដែលមិនមានរោគសញ្ញាអ្វីទាំងអស់ក៏ដោយ ក៏អាចចម្លងជំងឺទៅអ្នកដទៃទៀតបានដែរ** បន្ទាប់ពីមានការបង្ករោគបានពីរបីថ្ងៃ។

*ការព្យាបាល ៖*

- កាលពីមុន ជំងឺប្រមេះទឹកបាយត្រូវបានព្យាបាលដោយប្រើថ្នាំប៉េនីស៊ីលីន(Penicillin)។ ប៉ុន្តែសព្វថ្ងៃនេះ នៅតំបន់ជាច្រើន ជំងឺនេះបានក្លាយជាមានភាពស៊ាំជាមួយថ្នាំប៉េនីស៊ីលីន ដូច្នេះគេត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិកប្រភេទផ្សេងវិញ។ ជាការប្រសើរ ត្រូវស្វែងរកការណែនាំពីគ្រូពេទ្យនៅជិតបំផុត ថាតើថ្នាំណាមានប្រសិទ្ធភាពជាងគេអាចរកបាននៅ ក្នុងតំបន់របស់អ្នក និងមានតម្លៃដែលអាចទិញបាន។ ថ្នាំពេទ្យដែលប្រើសម្រាប់ព្យាបាលជំងឺប្រមេះទឹកបាយ និង ក្លាមីដ្យា មានបង្ហាញនៅ ទំ.៣៦០។ បើការស្រក់ខ្ទុះ និងការឈឺចាប់ គ្មានការជាសះស្បើយក្នុងរយៈពេល ២ទៅ ៣ថ្ងៃទេ មានន័យថាជំងឺប្រមេះទឹកបាយនេះអាចមានភាពស៊ាំជាមួយថ្នាំនោះ ឬអាចថាអ្នកនោះមានជំងឺក្លាមីដ្យា។
- បើស្ត្រីមានជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា ព្រមទាំងមានគ្រុនក្ដៅ និងការឈឺចាប់នៅក្នុងពោះ ផ្នែកខាងក្រោមផងនោះគាត់អាចមានជំងឺរលាកអាងត្រគាក (មើលទំ.២៤៣)។
- មនុស្សគ្រប់រូបដែលបានរួមភេទជាមួយមនុស្សដែលគេដឹងថាមានជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា ក៏គួរទទួលការព្យាបាលដែរ ជាពិសេសប្រពន្ធរបស់បុរសដែលមានជំងឺកាមរោគ។ បើទោះបីជាប្រពន្ធនោះមិនមានរោគសញ្ញាអ្វីក៏ ដោយ ក៏គាត់អាចមានជំងឺកាមរោគដែរ។ បើគាត់មិនព្យាបាលក្នុងពេលជាមួយគ្នានឹងប្ដីគាត់ទេ នោះគាត់នឹងចម្លងជំងឺ ទៅប្ដីគាត់វិញម្ដង។
- ការពារភ្នែករបស់ទារកពីជំងឺក្លាមីដ្យា ជាពិសេសពីជំងឺប្រមេះទឹកបាយ ដែលអាចបណ្ដាលឲ្យភ្នែករបស់ទារកខ្វាក់បាន(មើលទំ.២២១)។ សម្រាប់ការព្យាបាល សូមមើលទំ.៣៧៩។

*ប្រយ័ត្ន ៖* អ្នកកើតជំងឺប្រមេះទឹកបាយឬក្លាមីដ្យា ក៏អាចកើតជំងឺស្វាយដោយមិនដឹងខ្លួនផងដែរ។ ជួនកាល វាជាការល្អ ដែលត្រូវទៅព្យាបាលជំងឺស្វាយឲ្យបានចប់សព្វគ្រប់ ព្រោះការព្យាបាលជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា អាចបិទបាំងរោគសញ្ញាដំបូងនៃជំងឺរោគស្វាយ ប៉ុន្តែអាច**មិនបានព្យាបាលវាឲ្យជាទេ**។

ដើម្បីបង្ការជំងឺទាំងនេះ និងជំងឺកាមរោគផ្សេងៗទៀត សូមមើលទំ.២៣៩។

## ជំងឺស្វាយ

ជំងឺស្វាយជាជំងឺគ្រោះថ្នាក់ហើយកើតឡើងជាញឹកញាប់ ដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមការរួមភេទ។

*រោគសញ្ញា ៖*



- ជាទូទៅរោគសញ្ញាដំបូងគឺមានដំបៅ ហៅថាទាមឡា។ វាបង្ហាញឡើងក្នុងរយៈពេលពី២ទៅ៥សប្ដាហ៍ បន្ទាប់ពីបានរួមភេទជាមួយអ្នកកើតជំងឺស្វាយនេះ។ ទាមឡាមើលទៅស្រដៀងនឹងមុន ពងបែក ឬដូចដំបៅបើកមុខ។ តាមធម្មតា វា កើតនៅលើប្រដាប់ភេទបុរសឬស្ត្រី (ឬអាចចេញនៅលើបបូរមាត់ ម្រាមដៃ ទ្វារ លាមក ឬមាត់)។ ដំបៅនេះពោរពេញទៅដោយមេរោគ ដែលអាចឆ្លងទៅអ្នកដទៃ ទៀតបានយ៉ាងងាយ។ **ដំបៅនេះតែងតែគ្មានការឈឺចាប់ទេ ហើយបើវាស្ថិតនៅក្នុងរន្ធទ្វារមាស ស្ត្រីប្រហែលជាមិនដឹងថាគាត់មានដំបៅនេះទេប៉ុន្តែគាត់អាចចម្លងទៅអ្នកដទៃបានយ៉ាងងាយ។**



- ដំបៅនេះកើតឡើងតែពីរបីថ្ងៃប៉ុណ្ណោះ ហើយវាក៏បាត់ទៅវិញដោយមិនបាច់ព្យាបាល។ **ប៉ុន្តែជំងឺនេះនៅតែបន្តរាលដាលពេញរាងកាយ។**

- ជាច្រើនសប្តាហ៍ឬច្រើនខែក្រោយមក អាចមានការឈឺបំពង់ក គ្រុនក្តៅបន្តិចបន្តួច ដំបៅមាត់ ឬហើមសន្លាក់។ ឬអាចមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ បង្ហាញឡើងនៅលើស្បែក ៖


*កន្ទួលក្រហម ឈឺ ឬមានមុនពេញខ្លួនប្រាណ*


*ផ្ទាំងកន្ទួលរាងមូលៗ (ដូចកន្ទាលត្រអាក)*


*មានកន្ទួលរមាស់ នៅលើដៃឬជើង*

តាមធម្មតារោគសញ្ញាទាំងអស់នេះបាត់ទៅវិញដោយឯកឯង។ ហើយជារឿយៗអ្នកជំងឺគិតថាបានជាវិញហើយ ប៉ុន្តែតាមពិតជំងឺនៅតែមាននៅឡើយ។ **បើពុំបានព្យាបាលឲ្យបានពេញលេញទេ ជំងឺស្វាយអាចរាតត្បាតទៅគ្រប់ផ្នែកនៃរាងកាយ បណ្តាលឲ្យកើតជំងឺបេះដូង ខ្វិន វិកលចរិក និងបញ្ហាផ្សេងៗទៀតជាច្រើន។**

*សំគាល់ ៖ ជំងឺយ៉ស៍ក៏មានរោគសញ្ញាជាច្រើនដែលដូចគ្នានឹងជំងឺស្វាយដែរ។*

*ប្រយ័ត្ន ៖* បើមានកន្ទួលចម្លែក ឬបញ្ហាស្បែក ដែលកើតឡើងជាច្រើនថ្ងៃឬច្រើនសប្តាហ៍ បន្ទាប់ពីមានពងបែក ឬដំបៅលើប្រដាប់បន្តពូជ នោះវាអាចជាជំងឺស្វាយ។ ស្វែងរកដំបូន្មានពីគ្រូពេទ្យ។

*ការព្យាបាលជំងឺស្វាយ ៖* (**ដើម្បីឲ្យជាសះស្បើយជាស្ថាពរ ការព្យាបាលឲ្យបានពេញលេញគឺជាការចាំបាច់**)

- **បើរោគសញ្ញាកើតឡើងតិចជាងមួយឆ្នាំ** ចាក់ថ្នាំប៉េនីស៊ីលីនបេនហ្សាទីន (Benzathine Penicillin) ២,៤លានអ៊ុយនីតេ តែម្តង។ ចាក់ពាក់កណ្តាលនៃកម្រិតថ្នាំនៅកំប៉េះគូថម្ខាងៗ (មើលទំ.៣៥៣)។ អ្នកដែលមានប្រតិកម្មជាមួយថ្នាំប៉េនីស៊ីលីន អាចលេបតេត្រាស៊ីគ្លីន ៥០០មីលីក្រាម ៤ដងក្នុង១ថ្ងៃ រយៈពេល១៥ថ្ងៃ។
- **បើរោគសញ្ញាកើតឡើងលើសពីមួយឆ្នាំ** ចាក់ថ្នាំប៉េនីស៊ីលីនបេនហ្សាទីន ២,៤លានអ៊ុយនីតេ ពាក់កណ្តាលនៅកំប៉េះគូថម្ខាងៗ មួយអាទិត្យម្តង រយៈពេលបីអាទិត្យ ដែលសរុបគឺ៧,២លានអ៊ុយនីតេ។ បើមានប្រតិកម្មជាមួយថ្នាំប៉េនីស៊ីលីន លេបតេត្រាស៊ីគ្លីន៥០០មីលីក្រាម ៤ដងក្នុង១ថ្ងៃ រយៈពេល៣០ថ្ងៃ។
- បើសង្ស័យថានរណាម្នាក់កើតជំងឺស្វាយ គាត់គួរតែទៅជួបបុគ្គលិកសុខាភិបាល។ ការធ្វើតេស្តឈាមអាចជាការចាំបាច់។ បើមិនអាចធ្វើតេស្តឈាមទេ អ្នកនោះគួរតែព្យាបាលជំងឺស្វាយ ទោះបីក្នុងករណីណាក៏ដោយ។
- អ្នកដែលបានរួមភេទជាមួយមនុស្សដែលគេដឹងថាមានជំងឺស្វាយ ក៏គួរតែទទួលការព្យាបាលផងដែរ ជាពិសេសប្តីឬប្រពន្ធរបស់អ្នកដែលគេដឹងថាមានជំងឺនេះ។

*ចំណាំ ៖* ស្ត្រីមានផ្ទៃពោះឬស្ត្រីបំបៅកូនដោយទឹកដោះ ដែលមានប្រតិកម្មទំនាស់ជាមួយថ្នាំប៉េនីស៊ីលីន អាចលេបថ្នាំអេរីត្រូមីស៊ីន (Erythromycin) តាមកម្រិតដូចគ្នានិងថ្នាំតេត្រាស៊ីគ្លីនដែរ (មើលទំ.៣៥៦)។

ដើម្បីបង្ការជំងឺស្វាយ សូមមើលនៅទំព័របន្ទាប់។

## ហើមក្រលៀន ៖ ការធ្លាយកូនកណ្តុរនៅក្រលៀន



*រោគសញ្ញា ៖*

- **ចំពោះបុរស** ៖ ដុំពកធំពណ៌ខ្មៅនៅក្រលៀនដែលធ្លាយមុខហូរខ្ទុះ ជិតមុខវិញ និងធ្លាយមុខម្តងទៀត។
- **ចំពោះស្ត្រី** ៖ មានកូនកណ្តុរដូចបុរសដែរ ឬមានដំបៅ ដែលមានការឈឺចាប់ហូរខ្ទុះតាមរន្ធគូថ។

*ការព្យាបាល ៖*

- ទៅជួបបុគ្គលិកសុខាភិបាល
- សម្រាប់មនុស្សធំ ឲ្យថ្នាំតេត្រាស៊ីគ្លីន (Tetracycline) ២៥០មីលីក្រាម ២គ្រាប់ ៤ដងក្នុង១ថ្ងៃ រយៈពេល១៤ថ្ងៃ។
- ជៀសវាងការរួមភេទរហូតទាល់តែដំបៅបានជាសះស្បើយទាំងស្រុង។

*ចំណាំ ៖* ការហើមក្រលៀនក៏អាចជារោគសញ្ញានៃជំងឺទាមឡា (មើលទំ.៤០៣) ដែរ។

*វិធីបង្ការការឆ្លងរាលដាលនៃជំងឺកាមរោគ*

១. **ប្រុងប្រយ័ត្នជាមួយដៃគូរួមភេទរបស់អ្នក** ៖ អ្នកដែលមានដៃគូរួមភេទច្រើន ទំនងជាងាយឆ្លងជំងឺកាមរោគទាំងនេះណាស់។ ស្ត្រីរកស៊ីផ្លូវភេទងាយនឹងឆ្លងជាងគេ។ ដើម្បីជៀសវាងការឆ្លងជំងឺកាមរោគនេះ រួមភេទជាមួយដៃគូដែលស្មោះត្រង់តែម្នាក់គត់។ ប្រសិនបើអ្នករួមភេទជាមួយអ្នកដទៃទៀត **ប្រើស្រោមអនាម័យជានិច្ច**។ (ការប្រើស្រោមអនាម័យជួយបង្ការជំងឺកាមរោគ ប៉ុន្តែមិនធានាថាការពារបានទាំងស្រុងទេ)។

២. **ចាប់ផ្តើមព្យាបាលភ្លាមៗ** ៖ វាជាការសំខាន់ណាស់ដែលអ្នកឆ្លងជំងឺកាមរោគ ទទួលការព្យាបាលជាបន្ទាន់ ដើម្បីកុំឲ្យពួកគេចម្លងជំងឺនេះទៅអ្នកដទៃទៀត។ មិនត្រូវរួមភេទជាមួយមនុស្សដទៃទៀត រហូតដល់បាន៣ថ្ងៃ ក្រោយពីការព្យាបាលបានបញ្ចប់។ (ជាអកុសលមកទល់សព្វថ្ងៃនេះ នៅមិនទាន់មានការព្យាបាលជំងឺអេដស៍នៅឡើយទេ)។

៣. **ប្រាប់អ្នកដទៃទៀត បើគេត្រូវការការព្យាបាល** ៖ នៅពេលមនុស្សម្នាក់ដឹងថាគាត់មានជំងឺកាមរោគ គាត់គួរតែប្រាប់ដៃគូរួមភេទរបស់គាត់ឲ្យដឹង ដើម្បីឲ្យពួកគេទៅទទួលការព្យាបាលដែរ។ វាមានសារសំខាន់ណាស់ដែលបុរសត្រូវប្រាប់ស្ត្រី ព្រោះថាបើស្ត្រីមិនដឹងថាគាត់មានជំងឺកាមរោគទេ នោះគាត់អាចចម្លងទៅអ្នកដទៃទៀត ទារករបស់គាត់អាចឆ្លងជំងឺ ឬខ្វាក់ភ្នែក ហើយក្នុងពេលណាមួយ គាត់អាចក្លាយទៅជាអារ(មិនអាចមានកូន) ឬមានជំងឺធ្ងន់ធ្ងរ។

៤. **ជួយអ្នកដទៃ** ៖ ជំរុញមិត្តភក្តិដែលប្រហែលជាមានជំងឺកាមរោគ ឲ្យទៅព្យាបាលជាបន្ទាន់ ហើយប្រាប់ឲ្យពួកគេឲ្យជៀសវាងរួមភេទតាមគ្រប់វិធី រហូតដល់ពួកគេបានជាសះស្បើយ។

## របៀបប្រើនិងពេលដែលត្រូវប្រើ



## បំពង់បូមទឹកនោម (បំពង់កៅស៊ូសម្រាប់បង្ហូរទឹកនោមពីប្លោកនោម)

**ពេលដែលត្រូវប្រើ និងពេលដែលមិនត្រូវប្រើបំពង់បូមទឹកនោម ៖**

- មិនត្រូវប្រើបំពង់បូមទឹកនោមទេ លុះត្រាចាំបាច់បំផុត និងមិនអាចរកជំនួយពីគ្រូពេទ្យឲ្យទាន់ពេល។ សូម្បីតែការប្រើប្រាស់បំពង់បូមទឹកនោមដោយប្រុងប្រយត្ន័ក៏ដោយ ក៏ពេលខ្លះអាចបណ្តាលឲ្យមានការបង្ករោគដ៏គ្រោះថ្នាក់ ឬមានការខូចខាតដល់បង្ហូរនោមទៀតផង។
- ប្រសិនបើមានទឹកនោមហូរចេញមកខ្លះ មិនត្រូវប្រើបំពង់បូមទឹកនោមទេ។
- ប្រសិនបើអ្នកនោះមិនអាចនោមបាន ដំបូងឲ្យគាត់ព្យាយាមនោមក្នុងពេលអង្គុយក្នុងធុងទឹកក្តៅឧណ្ហៗ (ទំ.២៣៦)។ ចាប់ផ្តើមប្រើថ្នាំដែលបានណែនាំ(សម្រាប់ជំងឺប្រមេះទឹកបាយ ឬជំងឺក្រពេញប្រូស្តាត)។
- ប្រសិនបើគាត់មានទឹកនោមពេញក្នុងប្លោកនោម ហើយមានការឈឺចាប់នៅប្លោកនោម តែមិនអាចនោមបាន ឬប្រសិនបើគាត់ចាប់ផ្តើមបង្ហាញរោគសញ្ញានៃការពុលពីទឹកនោម ប្រើបំពង់បូមទឹកនោម។

*រោគសញ្ញានៃការពុលទឹកនោម(មានជាតិអ៊ុយរេក្នុងឈាម) ៖*



- ខ្យល់ដង្ហើមមានក្លិនដូចទឹកនោម។
- ហើមជើងនិងមុខ។
- ក្អួត មិនស្រួលក្នុងខ្លួន វង្វេងស្មារតី។

*ចំណាំ ៖* អ្នកដែលមានការឈឺចាប់ដោយពិបាកនោម រីកក្រពេញប្រូស្តាត ឬគ្រួសក្នុងតម្រងនោម គួរទិញបំពង់បូមទឹកនោម ហើយទុកវាសម្រាប់ប្រើប្រាស់ក្នុងគ្រាអាសន្ន។

## របៀបដាក់បញ្ចូលបំពង់បូមទឹកនោម

*១. ស្ងោរបំពង់បូមទឹកនោម (និងសឺរ៉ាំង ឬសំភារៈផ្សេងៗ ដែលអ្នកអាចប្រើ) រយៈពេល១៥នាទី។*



*២. លាងស្បែកនៅគ្របលិង្គ ឬទ្វារមាស និងផ្នែកដែលនៅជុំវិញឲ្យស្អាតជាមួយសាប៊ូនិងទឹកក្តៅឧណ្ហៗ។*




*៣. លាងសម្អាតដៃ បើអាច ប្រើសាប៊ូសម្រាប់លាងដៃ មុនពេលធ្វើការវះកាត់ (ដូចជា បេតាឌីន)។ ក្រោយពេល លាងដៃហើយ ប៉ះតែសម្ភារៈ ដែលស្ទេរីល ឬដែលស្អាត ប៉ុណ្ណោះ។*



*៤. ដាក់ក្រណាត់ស្អាតនៅខាងក្រោមនិងជុំវិញកន្ទែងនោះ*



*៥. ពាក់ស្រោមដៃស្ទេរីល ឬជុសជម្រះដៃ ជាមួយអាល់កុល ឬបេតាឌីន។*




*៦. លាបបំពង់បូមទឹកនោមដោយក្រមួនរំអិល ដែលរលាយក្នុងទឹក ដូចជា K-Y Jelly (មិនមែនប្រេង ឬវ៉ាស្លីលីនទេ)*



*៧. ទាញស្បែកគ្របលិង្គចុះក្រោម ឬញែកបើកបបូររបស់ទ្វារមាស*



*រួចជូតប្រហោងបង្ហូរនោមដោយសំឡីស្អាត ផ្សើមដោយសាប៊ូ*



*៨. កាន់ទប់ស្បែកលិង្គចុះមកក្រោម ឬបើកបបូរទ្វារមាស រួចដាក់បំពង់បូមទឹកនោមថ្នមៗចូលទៅក្នុងរន្ធនោម។ បង្វិលវាបន្តិចបើចាំបាច់ តែកុំបង្ខំ។*





*កាន់លិង្គឲ្យត្រង់ ដូចមុំនេះ។*

*៩. ចំពោះបុរស រុញបំពង់បូម ទឹកនោមចូលទៅក្នុងរហូតដល់មានទឹកនោមហូរមកក្រៅ រួចរុញចូល ៣សង់ទីម៉ែត្រទៀត។*

*ចំណាំ ៖ បង្ហូរនោមរបស់ស្ត្រី ខ្លីជាងបង្ហូរនោមរបស់បុរស។*



សំខាន់ ៖ បើនរណាម្នាក់មានសញ្ញានៃការពុលទឹកនោម ឬបើប្លោកនោមពេញពេក និងរីកធំ នោះមិនត្រូវឲ្យទឹកនោមហូរចេញមកក្រៅទាំងអស់តែម្តងទេ។ ផ្ទុយទៅវិញ ឲ្យវាចេញមកក្រៅយឺតៗ(ដោយច្របាច់ ឬបត់បំពង់) បន្តិចម្តងៗ រយៈពេល១ឬ២ម៉ោង។

ជួនកាលស្ត្រីមិនអាចនោមបាន បន្ទាប់ពីសម្រាលកូនរួច។ ប្រសិនបើលើស៦ម៉ោង ហើយប្លោកនោមរបស់គាត់ហាក់ដូចជាពេញ នោះគាត់ប្រហែលជាត្រូវប្រើបំពង់បូមទឹកនោមហើយ។ បើប្លោកនោមរបស់គាត់មិនពេញ នោះមិនត្រូវប្រើបំពង់បូមទឹកនោមទេ ប៉ុន្តែឲ្យគាត់ផឹកទឹកឲ្យបានច្រើនវិញ។

# បញ្ហាផ្សេងៗចំពោះស្ត្រី

## ការធ្លាក់ស (សំបោរឬខ្ទុះដែលចេញពីទ្វារមាស)

ជាធម្មតាស្ត្រីទាំងឡាយតែងមានធ្លាក់សបន្តិចបន្តួច ដែលមានពណ៌ថ្លាៗ ដូចទឹកដោះគោ ឬពណ៌លឿងខ្ចី។ ប្រសិនបើមិនរមាស់ ឬគ្មានក្លិនអាក្រក់ទេ ប្រហែលជាគ្មានបញ្ហាអ្វីទេ។

ប៉ុន្តែ ស្ត្រីជាច្រើន ជាពិសេសក្នុងពេលមានផ្ទៃពោះ មានបញ្ហាធ្លាក់ស ហើយជាញឹកញាប់មានរមាស់ក្នុងយោនីផង។ ការធ្លាក់សរបៀបនេះអាចបណ្តាលមកពីការបង្ករោគផ្សេងៗ។ ភាគច្រើននៃការបង្ករោគទាំងនេះ ធ្វើឲ្យមានការរំខានខ្លះៗ ប៉ុន្តែគ្មានគ្រោះថ្នាក់អ្វីឡើយ។ ទោះជាយ៉ាងនេះក្តី ការបង្ករោគដែលបណ្តាលមកពីជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា (Chlamydia) អាចបង្កគ្រោះថ្នាក់ដល់ទារកនៅពេលសម្រាល (មើលទំ.២២១)។

១. **ការធ្លាក់សរាវៗ ពពុះៗ ពណ៌បៃតងលាយលឿង ឬពណ៌ស មានក្លិនអាក្រក់ និងមានរមាស់។** នេះប្រហែលជាការបង្ករោគដោយ**ទ្រីកូម៉ូណាស់** (Trichomonas)។ វាអាចធ្វើឲ្យមានការឈឺក្រហាយនៅពេលនោម។ ជួនកាលអាចមានការឈឺចាប់ ឬហើមប្រដាប់ភេទ។ ការធ្លាក់សអាចមានលាយឈាម។

*ការព្យាបាល ៖*

- ការសម្អាតប្រដាប់ភេទឲ្យស្អាតជានិច្ច គឺជាការសំខាន់ណាស់។
- ការលាងសម្អាតទ្វារមាស ជាមួយទឹកក្តៅឧណ្ហៗ និងទឹកខ្មេះ អាចជួយបាន។ បើគ្មានទឹកខ្មេះ ប្រើទឹកក្រូចឆ្មាលាយជាមួយទឹក។

*សំខាន់ ៖* ឲ្យទឹកហូរយឺតៗ ក្នុងរយៈពេលប្រហែល៣នាទី។ មិនត្រូវដាក់បំពង់ចូលក្នុងទ្វារមាសឲ្យហួសពី៣អ៊ីញទេ។

*ចំពោះការធ្វើទឹកលាងទ្វារមាស ប្រើទឹកខ្មេះ ៦ស្លាបព្រាកាហ្វេ ក្នុងទឹកឆ្អិន ១លីត្រ។*





*ប្រយ័ត្ន ៖* ហាមលាងក្នុងអំឡុងពេល៤សប្តាហ៍ចុងក្រោយនៃការមានផ្ទៃពោះ ឬអំឡុងពេល៦សប្តាហ៍បន្ទាប់ពីសម្រាលកូន។ បើការធ្លាក់សមានការរំខាន ការសុលទ្វារមាសដោយ នីស្តាទីន (Nystatin) អាចជួយបាន (មើលលេខ២ នៅទំព័របន្ទាប់)។

- អ្នកក៏អាចប្រើខ្ទឹមសជាថ្នាំសុលទ្វារមាសបានដែរ។ (បកសំបកខ្ទឹម ដោយប្រយ័ត្នកុំចោះទម្លុះវា។ ខ្ចប់វានៅក្នុងបន្ទះក្រណាត់ស្អាត ឬកុំប្រេស រួចដាក់ចូលទៅក្នុងទ្វារមាស)។
- ប្រើទឹកលាងទ្វារមាស២ដងក្នុងពេលថ្ងៃ និងពេលយប់សុលដោយខ្ទឹមស។ ធ្វើដូចនេះរយៈពេល ១០ទៅ១៤ថ្ងៃ។
- បើការធ្វើរបៀបនេះមិនបានធូរស្រាលទេ ប្រើថ្នាំសុលទ្វារមាសដែលមានថ្នាំមីត្រូនីដាហ្សូល (Metronidazole) ឬថ្នាំផ្សេងទៀត ដែលបានណែនាំសម្រាប់ទ្រីកូម៉ូណាស់ ឬលេបថ្នាំមីត្រូនីដាហ្សូល។ ចំពោះការប្រុងប្រយ័ត្ន និងសេចក្តីណែនាំអំពីថ្នាំ សូមមើលទំព័រ៣៧០។

**សំខាន់ ៖** ប្តីរបស់ស្ត្រីដែលមានការបង្ករោគដោយទ្រីកូម៉ូណាស់ ក៏ទំនងជាមានជំងឺនេះដែរ ទោះបីជាគាត់មិនមានអារម្មណ៍ប្លែកក៏ដោយ។ (បុរសមួយចំនួនដែលមានទ្រីកូម៉ូណាស់ មានអារម្មណ៍ឈឺក្រហាយនៅពេលនោម)។ បើស្ត្រីត្រូវព្យាបាលដោយប្រើថ្នាំមីត្រូនីដាហ្សូល នោះប្តីរបស់គាត់ក៏គួរតែលេបថ្នាំនេះក្នុងពេលជាមួយគ្នាដែរ។

២. **ធ្លាក់សដូចជាទឹកដោះខាប់ និងមានក្លិនដូចផ្សិត ឬដូចនំប៉័ងជុត។** នេះអាចជា ការបង្ករោគដោយមេរោគផ្សិត (ម៉ូនីលីយ៉ាស៊ីស (Moniliasis) កង់ឌីដា(Candida))។ អាចមានការរមាស់ យ៉ាង ខ្លាំង។ ជារឿយៗបបូររបស់ទ្វារមាសឡើងក្លីរលោង និងមានការឈឺចាប់។ អាចមានការឈឺក្រហាយនៅពេល នោម។ ជំងឺនេះកើតឡើងជាញឹកញាប់លើស្ត្រីមានផ្ទៃពោះ ឬលើ អ្នកដែលមានជំងឺទឹកនោមផ្អែម(ទំ.១២៧) ឬអ្នកកំពុងប្រើថ្នាំអង់ទីប៊ីយ៉ូទិក ឬថ្នាំគ្រាប់ពន្យារកំណើត។

*ការព្យាបាល ៖* លាងសម្អាតទ្វារមាសដោយប្រើទឹកខ្មេះលាយទឹក(មើលទំ. ២៤១) ឬលាយហ្សង់ទ្យានវីយ៉ូឡេ។ ហ្សង់ទ្យានវីយ៉ូឡេ២ភាគ លាយជាមួយទឹក១០០ភាគ (២ស្លាបព្រាកាហ្វេ ជាមួយទឹកកន្លះលីត្រ)។ ឬប្រើថ្នាំគ្រាប់សុលទ្វារមាសនីស្តាទីន ឬថ្នាំសុលទ្វារមាសផ្សេងទៀត សម្រាប់ជំងឺម៉ូនីលីយ៉ាស៊ីស ឬកង់ឌីដា។ ចំពោះកម្រិតប្រើ និងសេចក្តីណែនាំអំពីថ្នាំ មើលទំព័រ៣៧០។ ការដាក់ទឹកដោះជូរទៅក្នុងទ្វារមាស គឺជាការព្យាបាលដែលត្រូវបានគេនិយាយថាជាការព្យាបាលតាមបែបបុរាណដ៏មានប្រយោជន៍មួយ ក្នុងការប្រឆាំងនឹងការបង្ករោគដោយមេរោគផ្សិត។ **មិនត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិកសម្រាប់ការបង្ករោគដោយមេរោគផ្សិតទេ។ វាអាចធ្វើឲ្យការបង្ករោគកាន់តែធ្ងន់ធ្ងរ។**

៣. **ទឹកខាប់ៗដូចទឹកដោះគោ និងមានក្លិនជូរ។** នេះអាចជាបង្ករោគដែលបណ្តាលមកពីបាក់តេរី។ គេអាចត្រូវការការធ្វើតេស្តពិសេស ដើម្បីឲ្យដឹងថាវាមិនមែនជាទ្រីកូម៉ូណាស់។ លាងសម្អាតទ្វារមាសដោយមានទឹកខ្មេះ និងទឹក (ទំ.២៤១) ឬដោយប៉ូវីដូន អ៊ីយ៉ូឌីន (បេតាឌីន(Betadine) ៦ស្លាបព្រាកាហ្វេ ក្នុងទឹក១លីត្រ)។ ម៉្យាងទៀតអ្នកក៏អាចសាកល្បងសុលដោយខ្ទឹមសជារៀងរាល់យប់ រយៈពេល២សប្តាហ៍(មើលទំ.២៤១)។ បើការព្យាបាលទាំងនេះមិនមានប្រសិទ្ធភាពទេ សាកល្បងប្រើថ្នាំមីត្រូនីដាហ្សូល។

៤. **ធ្លាក់ស រាវៗ ពណ៌ត្នោតឬប្រផេះ មានលាយឈាម មានក្លិនអាក្រក់ និងមានការឈឺចាប់នៅក្នុងពោះ** ផ្នែកខាងក្រោម។ ទាំងអស់នេះគឺជារោគសញ្ញានៃការបង្ករោគធ្ងន់ធ្ងរ ឬអាចជាជំងឺមហារីក(ទំ.២៨០)។ បើមានគ្រុនក្តៅ ប្រើថ្នាំអង់ទីប៊ីយ៉ូទិក (បើអាច ប្រើអំពីស៊ីលីនជាមួយតេត្រាស៊ីគ្លីន មើលទំ.៣៥៣ និង៣៥៦)។ ស្វែងរកជំនួយពីពេទ្យជាបន្ទាន់។

**សំខាន់ ៖** បើការធ្លាក់សនោះមានរយៈពេលយូរ ឬព្យាបាលមិនបានធូរស្រាល ទៅជួបបុគ្គលិកសុខាភិបាល។

## តើស្ត្រីអាចជៀសវាងជំងឺជាច្រើនបានដោយរបៀបណា

១. រក្សាអនាម័យត្រង់បរិវេណប្រដាប់ភេទ។ នៅពេលងូតទឹក(រាល់ថ្ងៃ បើអាច) លាងសម្អាតជាសាប៊ូបន្តិចបន្តួចឲ្យបានស្អាតល្អ។

២. ត្រូវនោម បន្ទាប់ពីរួមភេទរួច។ ការធ្វើរបៀបនេះអាចជួយបង្ការជំងឺប្រពន្ធ័ទឹកនោម (ប៉ុន្តែមិនបង្ការការមានផ្ទៃពោះទេ)។

៣. ត្រូវប្រាកដថាបានសម្អាតយ៉ាងត្រឹមត្រូវបន្ទាប់ពីបន្ទោរបង់លាមកម្តងៗ។ ត្រូវជូតពីមុខទៅក្រោយជានិច្ច ៖


*ជូតតាមរបៀបនេះ*


*កុំជូតតាមរបៀបនេះ*

ការជូតទៅខាងមុខ អាចចម្លងមេរោគ អាមីប ឬព្រូនទៅរន្ធនោម និងទ្វារមាស។ ម៉្យាងទៀត ត្រូវយកចិត្តទុកដាក់ជូតគូថឲ្យក្មេងស្រីពីមុខទៅក្រោយ និងបង្រៀនពួកគេ នៅពេលពួកគេធំឡើង ឲ្យធ្វើរបៀបនេះដែរ។

# ការឈឺចាប់ ឬការមិនស្រួលនៅក្នុងពោះ ផ្នែកកណ្តាលនិងខាងក្រោម លើស្ត្រី



បញ្ហានេះអាចបណ្តាលមកពីមូលហេតុផ្សេងៗជាច្រើន ដែលត្រូវបានពិភាក្សាដាច់ៗពីគ្នានៅ ក្នុងសៀវភៅនេះ។ ចំណុចខាងក្រោម ដែលមានបញ្ចូលសំនួរគន្លឹះមួយចំនួន នឹងជួយ អ្នកឲ្យដឹងអំពីកន្លែងដែលត្រូវពិនិត្យមើល។

មូលហេតុនៃការឈឺចាប់នៅក្នុងពោះ ផ្នែកខាងក្រោម មាន ៖

១. **ការធ្វើទុក្ខពេលមានរដូវ**( ទំ.២៤៦ )។ តើវាកាន់តែធ្ងន់ធ្ងរថែមទៀត នៅមុនពេលមានរដូវបន្តិច ឬក្នុងពេលកំពុងមានរដូវឬ ?

២. **ការបង្ករោគនៅប្លោកនោម**( ទំ.២៣៤ )។ ជាការឈឺចាប់ដែលមានជាញឹកញាប់បំផុតមួយក្នុងចំណោមការឈឺចាប់នៅក្នុងពោះផ្នែកខាងក្រោម។ តើនោមញឹកញាប់ ឬមានការឈឺចាប់ពេលនោមឬទេ ?

៣. **ជំងឺរលាកអាងត្រគាក។** ជំងឺនេះតែងតែជាដំណាក់កាលចុងក្រោយ នៃជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា( ទំ.២៣៦ ) ដោយមានការឈឺចាប់នៅក្នុងពោះផ្នែកខាងក្រោម និងមានគ្រុនក្តៅ។ បើរោគសញ្ញាទាំងនេះមានសភាពស្រាលព្យាបាលជំងឺប្រមេះទឹកបាយ( ទំ.៣៦០ ) និងឲ្យថ្នាំតេត្រាស៊ីគ្លីន( ទំ.៣៥៦ ) ឬ អេរីត្រូមីស៊ីន ( ទំ.៣៥៥ ) រយៈពេល១៤ថ្ងៃ។ ចំពោះរោគសញ្ញាធ្ងន់ធ្ងរឲ្យថ្នាំ មីត្រូនីដាហ្សូល៥០០មីលីក្រាម ៣ដងក្នុង១ថ្ងៃ រយៈពេល១០ថ្ងៃ។ បើស្ត្រីនោះ កំពុងប្រើកងដាក់ក្នុងស្បូន នោះអាចត្រូវយកចេញ។ ទៅជួបបុគ្គលិកសុខាភិបាល។

៤. **បញ្ហាដែលទាក់ទងនឹងការមានដុំនៅក្នុងពោះផ្នែកខាងក្រោម។** បញ្ហានេះត្រូវបានពិភាក្សាដោយសង្ខេបនៅទំព័រ ២៨០ ព្រមទាំងមានរួមបញ្ចូលទាំងការមានដុំនៅអូវែ និងជំងឺមហារីក។ គេអាចត្រូវការការពិនិត្យពិសេស ដោយបុគ្គលិកសុខាភិបាលជំនាញ។

៥. **ការមានគភ៌ក្រៅស្បូន**( នៅពេលដែលគភ៌ចាប់ផ្តើមលូតលាស់នៅខាងក្រៅស្បូន ទំ.២៨០ )។ ជាទូទៅ មានការឈឺចាប់យ៉ាងខ្លាំង ព្រមទាំងមានការធ្លាក់ឈាមជាច្រើន។ ជាញឹកញាប់ស្ត្រីនោះបង្ហាញរោគសញ្ញាដំបូងនៃការមានផ្ទៃពោះ( ទំ.២៤៧ ) ហើយមានអារម្មណ៍វិលមុខនិងខ្សោយ។ **ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ ជីវិតរបស់គាត់កំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់។**

៦. **ផលវិបាកបណ្តាលមកពីការរំលូតកូន**( ទំ.៤១៤ )។ អាចមានគ្រុនក្តៅ មានការធ្លាក់ឈាមតាមទ្វារមាស ឈឺពោះ ពិបាកនោម និងស្ពុក។ ចាប់ផ្តើមឲ្យថ្នាំអង់ទីប៊ីយ៉ូទិកដូចការព្យាបាលគ្រុនក្តៅបន្ទាប់ពីសម្រាលកូនដែរ( ទំ.២៧៦ ) រួច**បញ្ជូនស្ត្រីទៅមន្ទីរពេទ្យជាបន្ទាន់។ ជីវិតរបស់គាត់កំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់។**

៧. **ការបង្ករោគឬបញ្ហាផ្សេងៗទៀតដែលទាក់ទងនឹងពោះវៀនឬចង់លាមក**( ទំ.១៤៥ )។ តើការឈឺចាប់ទាក់ទងជាមួយនឹងការបរិភោគ ឬជាមួយនឹងការបន្ទោរបង់លាមកឬទេ ?

បញ្ហាមួយចំនួនដូចបានរៀបរាប់ខាងលើនេះ គ្មានសភាពធ្ងន់ធ្ងរទេ។ តែខ្លះទៀត មានគ្រោះថ្នាក់យ៉ាងខ្លាំង។ បញ្ហាទាំងនោះមិនមែនសុទ្ធតែងាយញែកឲ្យដាច់ពីគ្នាទេ។ គេអាចត្រូវការការធ្វើតេស្តឬការពិនិត្យពិសេស។

**បើអ្នកមិនដឹងច្បាស់អំពីមូលហេតុដែលបណ្តាលឲ្យមានការឈឺចាប់**
**ឬបើវាគ្មានការធូរស្រាលក្នុងពេលឆាប់ៗទេ ស្វែងរកជំនួយពីគ្រូពេទ្យ។**

# បុរសនិងស្ត្រីដែលមិនអាចមានកូនបាន(អារ)

ជួនកាលបុរសនិងស្ត្រីព្យាយាមឲ្យមានកូន តែស្ត្រីមិនមានផ្ទៃពោះ។ បញ្ហានេះអាចដោយសារបុរសឬស្ត្រីនោះមានភាពអារ(មិនអាចធ្វើឲ្យមានផ្ទៃពោះ)។ ជាញឹកញាប់ គេមិនអាចធ្វើឲ្យមនុស្សម្នាក់ក្លាយជាអាចមានកូនវិញបានទេ ប៉ុន្តែពេលខ្លះ វាក៏អាចដែរ គឺអាស្រ័យលើមូលហេតុរបស់វា។

**មូលហេតុញឹកញាប់នៃភាពមិនមានកូន ៖**

១. **ភាពអារ។** រាងកាយរបស់មនុស្សនេះ មិនអាចមានកូនសោះ។ បុរសនិងស្ត្រីខ្លះមានភាពអារតាំងពីកំណើតមកម្ល៉េះ។

២. **ការខ្សោយ ឬការខ្វះអាហារូបត្ថម្ភ។** ចំពោះស្ត្រីមួយចំនួន ភាពស្លេកស្លាំងធ្ងន់ធ្ងរ ការខ្វះអាហារូបត្ថម្ភ ឬការខ្វះជាតិអ៊ីយ៉ូដ អាចកាត់បន្ថយឱកាសក្នុងការមានផ្ទៃពោះ។ ឬអាចបណ្តាលឲ្យទារកដែលមិនទាន់សម្រាល ទៅជាស្លាប់ក្នុងផ្ទៃ ជួនកាលមុនពេលស្ត្រីដឹងថាគាត់មានផ្ទៃពោះទៅទៀត(មើលការរំលូតកូន ទំ.២៨១)។ ស្ត្រីដែលមិនអាចមានផ្ទៃពោះ ឬធ្លាប់មានតែការរលូតកូន គួរទទួលអាហារូបត្ថម្ភឲ្យបានគ្រប់គ្រាន់ ប្រើអំបិលអ៊ីយ៉ូដ ហើយបើគាត់មានភាពស្លេកស្លាំងធ្ងន់ធ្ងរ ត្រូវលេបថ្នាំគ្រាប់ជាតិដែក(ទំ.២៤៧)។ វិធីនេះអាចបង្កើនឱកាសក្នុងការមានផ្ទៃពោះ ព្រមទាំងធ្វើឲ្យទារកមានសុខភាពល្អបាន។

៣. **ជំងឺរ៉ាំរ៉ៃ** ជាពិសេសជំងឺរលាកអាងត្រគាក(ទំ.២៤៣) ដែលបណ្តាលមកពីជំងឺប្រមេះទឹកបាយ និងក្លាមីដ្យា គឺជាមូលហេតុញឹកញាប់ដែលបណ្តាលឲ្យស្ត្រីគ្មានកូន។ ការព្យាបាលអាចជួយដែរ បើជំងឺនោះមិនទាន់មានសភាពធ្ងន់ធ្ងរនៅឡើយ។ ការបង្ការ និងការព្យាបាលជំងឺប្រមេះទឹកបាយ និងក្លាមីដ្យាបានទាន់ពេល មានន័យថាមានស្ត្រីអារកាន់តែតិច។

៤. ជួនកាល**បុរស**មិនអាចធ្វើឲ្យស្ត្រីមានផ្ទៃពោះបាន ដោយសារតែគាត់មានមេជីវិតតិចជាងធម្មតា។ វិធីមួយដែលអាចជួយដែរ គឺឲ្យបុរសនោះរង់ចាំ ដោយមិនរួមភេទរយៈពេលជាច្រើនថ្ងៃមុនពេលដែលស្ត្រីចូល ដល់ថ្ងៃដែលអាចមានការបង្កកំណើត ក្នុងខែនីមួយៗ ដែលថ្ងៃទាំងនោះគឺជាថ្ងៃដែលស្ថិតនៅពាក់កណ្តាល ពីថ្ងៃមានរដូវលើកមុន និងថ្ងៃមានរដូវបន្ទាប់ (មើលវិធីពិនិត្យថ្ងៃខែ និងវិធីពិនិត្យទឹករំអិល ទំ.២៩១និង២៩២)។ តាមមធ្យោបាយនេះ បុរស នោះនឹងផ្តល់ឲ្យស្ត្រីនូវមេជីវិតពេញលេញនៅពេលរួមភេទនៅថ្ងៃដែលស្ត្រីអាចមានផ្ទៃពោះបាន។

*ប្រំាម ៖* អ័រម៉ូននិងថ្នាំដទៃទៀតដែលគេច្រើនឲ្យបុរសឬស្ត្រីដែលមិនអាចមានកូន គឺស្ទើរតែគ្មានប្រយោជន៍អ្វីទាំងអស់ ជាពិសេសចំពោះបុរស។ ឱសថបុរាណ និងការព្យាបាលដោយមន្តអាគម ក៏មិនអាចជួយបានដែរ។ ប្រយត្ន័ ដោយកុំខ្ជះខ្ជាយលុយកាក់ទៅលើអ្វីដែលមិនជួយអ្នកសោះ។

បើអ្នកជាស្ត្រីដែលមិនអាចមានកូន អ្នកនៅតែមានលទ្ធភាពជាច្រើនដើម្បីធ្វើឲ្យជីវិតរស់មានសុភមង្គល និងមានតម្លៃបាន ៖



- ជួនកាលអ្នកអាចសុំកុមារកំព្រាឬកុមារដែលត្រូវការផ្ទះសម្បែង មកចិញ្ចឹម។ ប្តីប្រពន្ធជាច្រើនស្រឡាញ់កូនចិញ្ចឹម ដូចជាកូនបង្កើតរបស់ខ្លួនដែរ។
- ជួនកាលអ្នកអាចក្លាយជាបុគ្គលិកសុខាភិបាល ឬជួយសហគមន៍របស់អ្នកតាមមធ្យោបាយផ្សេងៗ។ ក្តីស្រឡាញ់ដែលអ្នកនឹងផ្តល់ឲ្យកូនរបស់អ្នក ក៏អាចផ្តល់ទៅឲ្យអ្នកដទៃទៀតដែរ ហើយវាសុទ្ធតែមានប្រយោជន៍ទាំងអស់។
- អ្នកអាចរស់នៅក្នុងភូមិមួយដែលប្រជាជនមើលងាយលើស្ត្រីដែលមិនអាចមានកូន។ ជួនកាលអ្នក និងអ្នកដទៃទៀតអាចបង្កើតជាក្រុមមួយ ដើម្បីជួយអ្នកដែលត្រូវការការគាំទ្រពិសេស និងដើម្បីបង្ហាញថា ការមានកូន មិនមែនជាវត្ថុតែម្យ៉ាងដែលធ្វើឲ្យស្ត្រីមានតម្លៃនោះទេ។